**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តត្បូងឃ្មុំ**
លេខៈ ៣៥៨/២១ រដ្ឋបាល.តឃ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំសណ្តាប់ធ្នាប់ លើការសាងសង់ ការបើកផ្លូវចូលគេហដ្ឋាន ការចាក់បំពេញអាចម៍ដី និងការពុះដីឡូត៍ ស្ថិតក្នុងតំបន់រដ្ឋបាលខេត្តត្បូងឃ្មុំ

**យោង** ៖ សេចក្តីសម្រេចលេខ ០៧៨ សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ របស់គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ជាតិ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីក្រុងទីរួមខេត្តត្បូងឃ្មុំ ។

រដ្ឋបាលខេត្ត ពិនិត្យឃើញថា ដីនៅក្នុងតំបន់ប្លង់គោលនៃទីរួមខេត្តត្បូងឃ្មុំ មានតំបន់ខ្លះត្រូវបានបងប្អូនប្រជាពលរដ្ឋមួយចំនួន បានកំពុងដាក់អាចម៍ដី គ្រោងនឹងសាងសង់សំណង់ និងកន្លែងមួយចំនួនទៀត កំពុងតែមានការបើកផ្លូវ សម្រាប់ធ្វើជាច្រកចេញចូល ធ្វើឱ្យមានការបាត់បង់នូវសោភ័ណភាព និងប៉ះពាល់ហេដ្ឋារចនាសម្ព័ន្ធ ដែលបានកំណត់ដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីក្រុងនៃទីរួមខេត្តត្បូងឃ្មុំ ។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាល ក៏ដូចជារដ្ឋបាលខេត្ត បាននឹងកំពុងអភិវឌ្ឍន៍នូវហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ដូចជា សំណង់អគារ ផ្លូវថ្នល់ លូ ស្ពាន អាងទឹក អគ្គិសនី ប្រព័ន្ធបណ្តាញទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងទឹកកខ្វក់...។ល។ ទៅតាមប្លង់គោលប្រើប្រាស់ដីធ្លីក្នុងទីតាំងនានានៃទីរួមខេត្តត្បូងឃ្មុំ។

ដូច្នេះដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន សុវត្ថិភាព សោភ័ណភាព និងរួមចំណែកក្នុងការអភិវឌ្ឍន៍ តំបន់ខាងលើនេះ ស្របតាមគោលការណ៍ប្លង់គោលប្រើប្រាស់ដីធ្លី និងផែនការប្រើប្រាស់ដីក្រុងក្នុងខេត្តត្បូងឃ្មុំឱ្យបានល្អប្រសើរ។

រដ្ឋបាលខេត្តត្បូងឃ្មុំ សូមជូនដំណឹងដល់ សាធារណជនដែលមានកម្មសិទ្ធដីធ្លីនៅក្នុងតំបន់រដ្ឋបាលខេត្តដូចខាងក្រោម៖

១.ត្រូវធ្វើការស្នើសុំលិខិតអនុញ្ញាតមករដ្ឋបាលខេត្ត រាល់ការសាងសង់ ការបើកផ្លូវ ការចាក់បំពេញអាចម៍ដី និងការពុះដីឡូត៍ ស្របតាមនីតិវិធី។


អាសយដ្ឋាន : ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (855) 45 211 118, អ៊ីមែល : tboungkhmum.tkm@gmail.com
Address : Nikom Leu Village, Sralab Commune, Tboung Khmum District, Tboung Khmum Province, Tel (855-42)211 118E-mail : tboungkhmum.tkm@gmail.com

២.ត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស ដែលមានចែងក្នុងប្លង់គោល ដោយកំណត់យកប្រវែង៥.៥០ម៉ែត្រ និងត្រូវចាក់ទំនាប់ស៊ីម៉ង់ត៍ទ្រាប់បាត រាល់ការបើកផ្លូវក្បៀឡា ដើម្បីបង្កើនភាពរឹងមាំ។

៣.ហាមដាច់ខាតមិនឱ្យមានការសាងសង់សំណង់ ការកែប្រែប្រភេទដី (ការជីកយកដីចាក់បំពេញដី-លុបដី និងការបែងចែកពុះដីឡូត៍លក់) ដោយមិនមានការចុះពិនិត្យ សិក្សាលក្ខណៈបច្ចេកទេស ស្របតាមនីតិវិធី និងការអនុញ្ញាតពីរដ្ឋបាលខេត្តជាមុន។

៤.ក្នុងករណីមិនគោរពតាមការណែនាំខាងលើ រដ្ឋបាលខេត្ត នឹងចាត់វិធានការតាមផ្លូវច្បាប់ និងមិនទទួលខុសត្រូវរាល់ការខាតបាត់បង់ផលប្រយោជន៍ របស់ប្រជាពលរដ្ឋ ដែលកើតមានឡើងពីការប្រព្រឹត្តិផ្ទុយនឹងការណែនាំនេះ។

ទទួលបានសេចក្ដីជូនដំណឹងខាងលើនេះ រដ្ឋបាលខេត្ត មានក្ដីសង្ឃឹម និងជឿជាក់ថា សាធារណជនទាំងអស់ ដែលមានកម្មសិទ្ធដីធ្លីនៅក្នុងតំបន់ខាងលើ ត្រូវអនុវត្តតាមការណែនាំឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ថ្ងៃ[illegible] ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ត្បូងឃ្មុំ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១

**អភិបាលខេត្ត**

ជាម_ច័ន្ទសោភ័ណ

**ចម្លងជូន៖**

-មន្ទីរអង្គភាពជុំវិញខេត្ត

-គ្រប់សាលាក្រុង-ស្រុក

-គ្រប់ឃុំសង្កាត់

"<u>ដើម្បីផ្សព្វផ្សាយ</u>"

-ឯកសារ-កាលប្បវត្តិ